**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Feb-2012, 13:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អវតក ("វិធានផ្ទៃក្នុង")[1] មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") ដាក់សំណើនេះសុំចំណាត់ការជាបន្ទាន់ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ សម្រាប់មូលហេតុទាំងអស់ដែលបញ្ជាក់នៅខាងក្រោម ក្រុមមេធាវីការពារក្តីស្នើឲ្យពិចារណាថា (ក) សំណើសុំនេះអាចទទួលយកបាន (ខ) ការកត់សម្គាល់នាពេលថ្មីៗនេះដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់សារព័ត៌មានវៀតណាមជាការរំលោភសិទ្ធិរបស់ នួន ជា ដែលត្រូវសន្មតជាមុនថាគ្មានទោសនៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចាត់ទុកថាការជ្រៀតជ្រែកមកក្នុងការងាររបស់តុលាការនៅ អវតក និង, (គ) អង្គជំនុំជម្រះត្រូវតែផ្តល់នូវដំណោះស្រាយដ៏មានប្រសិទ្ធិភាព និងមានប្រយោជន៍។ ដោយសារបញ្ហានេះជាបញ្ហាបឋម មេធាវីការពារក្តី ប្រកាន់ជំហាថាសំណើនេះត្រូវតែចំណាត់ថ្នាក់ជាឯកសារធារណៈ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយក្រុមមេធាវីការពារក្តីចាត់ទុកសំណើនេះជាសាធារណៈ។

## II. អង្គហេតុពាក់ព័ន្ធ

### ក. ការកត់សម្គាល់ជាសាធារណៈរបស់លោក ហ៊ុន សែន ទាក់ទងនឹង នួន ជា

២. អង្គហេតុចំពោះសំណើនេះ គឺមានលក្ខណៈចំៗ។ កាលពីថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ មានការចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មានវៀតណាមថាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការកត់សម្គាល់ដូចខាងក្រោម នៅពីរថ្ងៃមុនសន្និសីទសារព័ត៌មាននៅខេត្ត Dong Nai ប្រទេសវៀតណាម:

> ការអធិប្បាយពីការចោទប្រកាន់ដោយមេដឹកនាំខ្មែរក្រហមនៅឯសវនាការកាត់សេចក្តី កាលពីខែកន្លងទៅថាប្រទេសវៀតណាមបានឈ្លានពានប្រទេសកម្ពុជានៅទសវត្សទីឆ្នាំ៧០, ហ៊ុន សែន និយាយថាវាមិនចាំបាច់ឆ្លើយតបទៅនឹងពាក្យសំដី "បោកប្រាស់ហ្នឹងទេ" ។

---

[1] សូមមើលវិធានផ្ទៃក្នុង អវតក (វិសោធនកម្មទី៨) ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១ ។

> ឃាតក និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍កំពុងតែការពារខ្លួនដែលជាកិច្ចប្រឹងប្រែងមួយដើម្បីធ្វើឱ្យផុតពីឧក្រិដ្ឋកម្ម ។ គេគ្រប់គ្នាដឹងថាប្រទេសរបស់យើងធ្លាប់មានរបបប្រល័យពូជសាសន៍ ហើយឥឡូវនេះយើង និងពិភពលោកដំណើរការកាត់ទោសពួកគេ"[2] ។

គ្មានមន្ទិលសង្ស័យនោះទេលោកនាយករដ្ឋមន្ត្រីនិយាយសំដៅលើ នួន ជា ដែលជាមេដឹកនាំខ្មែរក្រហមតែម្នាក់គត់បានផ្តល់សក្ខីកម្មនៅសវនាការនាខែ ធ្នូ ឆ្នាំ ២០១១ អំពីការចូលឈ្លានពានរបស់វៀតណាមមកលើកម្ពុជានាទសវត្សឆ្នាំ១៩៧០ ។

## ខ. មេធាវីការពារក្តីខិតខំលើកបញ្ហានេះនៅតុលាការ

៣. នៅឱកាសលើកដំបូង មេធាវីការពារក្តីជំទាស់ទៅនឹងការថ្លែងទាំងនេះនៅចំពោះមុខតុលាការ និងបានស្នើសុំឱ្យអង្គជំនុំជម្រះដាក់វិធានការសមស្រប[3]។ ជាពិសេសមេធាវីការពារក្តីស្វែងរកឱ្យមានដំណោះ

---

[2] Minh Nam, Tan Tu, and An Dien, វៀមណាមមិនបានឈ្លានពានោះទេ បានសង្គ្រោះប្រទេសកម្ពុជាទៅវិញទេ។ *Than Nien News/Vietweek*,ចុះផ្សាយថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ (ចម្លងឡើងវិញដោយ អវតក media clipping-7-9 ខែមករា ឆ្នាំ២០១២) អាចរកបាននៅ ។ available at: http://www.thanhniennews.com/2010/pages/20120105-vietnam-did-not-invade--but-revived-cambodia--hun-sen.aspx.

[3] ឯកសារ E1/24.1 ប្រតិចារិតនៃដំណើរការជំនុំជម្រះ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ERN 00767596–00767710, (សវនាការថ្ងៃ១២) ទំព័រ ១: ២៤-៣: ១៦ ។ (កាលពីម្សិលមិញ ខ្ញុំបានទទួល press clippping មិនធម្មតាមួយដែលត្រូវបានចែកចាយនៅក្នុងតុលាការនេះ ហើយមានអត្ថបទមួយនៅក្នុង press clippping បានដកស្រង់សំដីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសន្និសីទសារព័ត៌មានកាលពីសប្តាហ៍កន្លងទៅនៅប្រទេសវៀតណាម នៅក្នុងសន្និសីទសារព័ត៌មាននោះ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា [..] ការថ្លែងរបស់ នួន ជា នៅតុលាការនាខែធ្នូ ជាការបោកបញ្ឆោត ។ នោះគឺជាសំដីដែលគាត់ប្រើ យោងទៅតាមអ្នកសារព័ត៌មាន ហើយបន្ថែមពីលើនេះ គាត់បានហៅនួន ជា (កូនក្តីរបស់យើងខ្ញុំ) "ជាឃាតក" និង "ជនដៃដល់នៃអំពើប្រល័យពូជសាសន៍" ។ នេះគឺជាការថ្លែងយ៉ាងច្បាស់អំពីទោសកំហុសរបស់ នួន ជា ដោយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា ហើយការថ្លែងបែបនេះជាការរំលោភយ៉ាងខ្ពស់ទៅលើសិទ្ធិរបស់កូនក្តីយើងខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយអ្វីដែលសំខាន់ជាងទៅទៀតនោះគឺការរំលោភសិទ្ធិរបស់ នួន ជា ក្នុងការ ទទួលបានការសន្មតជាមុនថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ វាមិនអាស្រ័យលើលោកនាយករដ្ឋមន្ត្រីទេដែលត្រូវសម្រេចថា តើកូនក្តីរបស់យើងខ្ញុំមានទោសកំងហុស ឬមិនមានទោសកំហុសនោះ តែវាជាកិច្ចការរបស់ លោក/លោកស្រីចៅក្រមនៅតុលាការទេដែលត្រូវសម្រេច ។ មានរឿងក្តីដ៏ល្បីមួយនៅតុលាការអឺរ៉ុបសិទ្ធិមនុស្ស គឺករណី Allenet de Ribemont ប្រឆាំងនឹងប្រទេសបារាំងដែលមានចំណុចជាច្រើនស្រដៀងនឹងករណីនេះ ហើយយើងខ្ញុំសូមលើកទឹកចិត្តឱ្យតុលាការនេះពិនិត្យមើលសេចក្តីសម្រេចលើរឿងក្តីនេះ ។ តុលាការអឺរ៉ុបសិទ្ធិមនុស្សបានលើកឡើងថាការកត់សម្គាល់ដោយមន្ត្រីសារធារណៈនៅក្នុងរឿងក្តីនោះអំពីទោសកំហុសរបស់ជនជាប់ចោទ "បានជម្រុញឱ្យសារធារណជន ជឿជាក់ថាជនជាប់ចោទ

ស្រាយដូចខាងក្រោម (សំណើផ្ទាល់មាត់): យើងខ្ញុំស្នើសុំឲ្យលោក/លោកស្រីចៅក្រមថ្កោលទោសជាផ្លូវការទៅលើការថ្លែងទាំងនេះ ដែលធ្វើឲ្យប៉ះពាល់ដល់កូនក្តីយើងខ្ញុំ និងរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងស្នើសុំលោកនាយករដ្ឋមន្ត្រីបញ្ឈប់ការថ្លែងបែបនេះតទៅទៀតនាពេលអនាគត[4]។ ការខកខានមិនទទួលស្គាល់សូម្បីតែសំណើផ្ទាល់មាត់ លោកប្រធានអង្គជំនុំជម្រះបានរំកិលទៅប្រធានបទបន្ទាប់នៅក្នុងរបៀបវារៈសវនាការរបស់គាត់[5]។ សហព្រះរាជអាជ្ញារងអន្តរជាតិបានកត់សម្គាល់ដ៏ខ្លីថាការិយាល័យរបស់គាត់ប្រាកដថាអង្គជំនុជម្រះនឹងមិនអនុញ្ញាតឲ្យការថ្លែងរបស់លោកនាយករដ្ឋមន្ត្រីជ្រៀតជ្រែកក្នុងឯករាជ្យភាពរបស់ចៅក្រមនោះទេ[6]។ ជាថ្មីម្តងទៀត ពុំមានការទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូងឡើយ[7]។

៤. ប្រាំបួនថ្ងៃក្រោយមក ដោយពុំមានចំណាត់ការសមស្របពីសំណាក់អង្គជំនុំជម្រះសាលាដំបូងលើសំណើផ្ទាល់មាត់របស់យើងខ្ញុំ មេធាវីការពារក្តីបញ្ជាក់ជាថ្មីអំពីការអំពាវនាវរបស់ខ្លួនដើម្បីថ្កោល

---

មានទោសកំហុស" ហើយថាពួកគេបានបុរេវិនិច្ឆ័យការវាយតម្លៃអង្គហេតុដោយអាជ្ញាធរតុលាការ ដែលបានសម្រេចលើបញ្ហា ឬពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ការថ្លែងបែបនេះដោយមន្ត្រីជាន់ខ្ពស់បានដាក់សំពាធមកលើ តុលាការនេះ តុលាការណាមួយដើម្បីវិនិច្ឆ័យទោស ហើយការថ្លែងបែបនេះក៏ប៉ះពាល់ដល់ឯករាជរបស់ចៅក្រមនៅក្នុងតុលាការដែរ។ វាពិតណាស់ថានៅប្រទេសនេះដែលមានប្រព័ន្ធតុលាការទន់ខ្សោយ ការថ្លែងបែបនេះ-ហើយជាជំហដ៏រឹងមាំរបស់យើងខ្ញុំ តម្រូវឲ្យតុលាការនេះឆ្លើយតបខ្លាំងៗផងដែរ ។ យើងខ្ញុំស្នើសុំឲ្យលោក/លោកស្រីចៅក្រមថ្កោលទោសជាផ្លូវ ការទៅលើការថ្លែងបែបនេះដែលប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា និងបានរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសូមស្នើឲ្យលោកនាយករដ្ឋមន្ត្រីបញ្ឈប់ការថ្លែងបែបនេះនាពេលអនាគត ។ លោក/លោកស្រីចៅក្រមត្រូវការពារបូរណភាពរបស់តុលាការនេះ" ។

[4] ដូចខាងលើទំព័រ 3:11-14 ។

[5] ដូចខាងលើទំព័រ 3:19 ។

[6] ដូចខាងលើទំព័រ 7:10 (ប្រហែលតែមួយចំណុចទៀតទេ ទាក់ទងនឹងការថ្លែងរបស់មេធាវីការពារក្តី នួន ជា អំពីការកត់ សម្គាល់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ការិយាល័យសហព្រះរាជអាជ្ញាមានទំនុកចិត្តយ៉ាងម៉ឺតមាំទៅលើអង្គជំនុំ ជម្រះនេះ ថានឹងពុំមានសាធារណជនណាម្នាក់ ឬមន្ត្រីសាធារណៈណាម្នាក់នឹងជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់លោក/លោកស្រីចៅក្រមដែលឯករាជ្យក្នុងការសម្រេចដែលសំអាងលើភស្តុតាង មិនសំអាងលើការចោទប្រកាន់តែស្មានៗនៅក្នុងសារព័ត៌មាន ឬនៅទីសាធារណៈផ្សេងៗនោះទេ ។

[7] ដូចខាងលើទំព័រ 7:17 ។

ទោសការកត់សម្គាល់ និងការក្រើនរំលឹកអំពីការថ្លែងបែបនេះ[8]។ ការបញ្ចេញប្រតិកម្មដើម្បីឱ្យរួចខ្លួន និងយ៉ាងគ្រោតគ្រាត ប្រធានអង្គជំនុំជម្រះប្រាប់មេធាវីការពារក្តីថាអង្គជំនុំជម្រះមិនមានមតិយោបល់ទេ ហើយថាមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឱ្យលើកបញ្ហានេះនៅក្នុងតុលាការទេ[9]។

៥. នៅសវនាការនាថ្ងៃបន្ទាប់មេធាវីការពារក្តីប៉ុនប៉ងសារជាថ្មី ដើម្បីអូសទាញការឆ្លើយតបពីអង្គជំនុំជម្រះ និងដើម្បីបំភ្លឺការកត់សម្គាល់លើកមុនរបស់ប្រធានអង្គជំនុំជម្រះ "តើវាជាសេចក្តីសម្រេចមែនឬ? [...] ឬលោកប្រធានគ្រាន់តែប្រាប់ខ្ញុំថា ខ្ញុំត្រូវតែស្ងៀមស្ងាត់ ហើយសេចក្តីសម្រេចមួយនឹងធ្វើឡើងឆាប់ៗនេះ? ហើយប្រសិនបើមានសេចក្តីសម្រេចមែន លោកប្រធាន អាចប្រាប់ខ្ញុំបានទេថា តើខ្ញុំអាចរំពឹងទុកអំពីសេចក្តីសម្រេចហ្នឹងនៅពេលណាដែរ?[10]។ បន្ទាប់មកប្រធានអង្គជំនុំជម្រះប្រគល់វេទិកាឱ្យលោកស្រីចៅក្រម Cartwright[11] ដែលប្រកាសអំពីជំហរទាក់ទងនឹងសំណើផ្ទាល់មាត់ "បញ្ហានេះនឹងត្រូវពិចារ

---

[8] ឯកសារ E1/30.1 ប្រតិចារិតនៃដំណើរការជំនុំជម្រះ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ (ថ្ងៃសវនាការទី១៨) ERN 00771977–00772091, pp 112:20–113:6 (អរគុណលោក/លោកស្រីចៅក្រម ខ្ញុំគ្រាន់តែចង់បញ្ជាក់ឡើងវិញពីសំណើរបស់យើងខ្ញុំកាលពីសប្តាហ៍មុន បន្ទាប់ពីការកត់សម្គាល់ជាសាធារណៈដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពីកូនក្តីរបស់យើងខ្ញុំ ។ លោក/លោកស្រីចៅក្រមប្រហែលជាចាំហើយលោកនាយករដ្ឋមន្ត្រីហៅកូនក្តីរបស់យើងខ្ញុំថា ជាឃាតក និងជនដែលដល់នៃអំពើប្រល័យពូជសាសន៍ ហើយគាត់ហៅ-គាត់ចាត់ទុកថាការថ្លែងរបស់ នួន ជា ជាការបោកបញ្ឆោត ។ បន្ទាប់មកយើងខ្ញុំស្នើឱ្យអង្គជំនុំជម្រះនេះចាត់វិធានសមស្របដើម្បីថ្កោលទោសប្រឆាំងនឹងការថ្លែងបែបនេះដោយលោកនាយករដ្ឋមន្ត្រី និងស្នើឱ្យគាត់បញ្ឈប់ការថ្លែងបែបនេះនាពេលអនាគត ។ យើងខ្ញុំគ្រាន់តែចង់ដឹងថាតើនៅពេលណាយើងខ្ញុំ អាចឃើញការសម្រេចលើសំណើពិសេសនេះ ។

[9] ឯកសារ E1/30.1 ប្រតិចារិតនៃដំណើរការជំនុំជម្រះ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ (ថ្ងៃសវនាការទី១៨) ERN 00771977–00772091, pp 113:8–12 (អង្គជំនុំជម្រះបានកត់សម្គាល់អំពីការថ្លែងដោយមេធាវីការពារក្តី ។ វាហាក់ដូចជាថាមេធាវីការពារក្តីអន្តរជាតិឱ្យ នួន ជា ហាក់ដូចច្រាំដែល ហេតុដូច្នេះយើងមិនចាំបាច់ធ្វើការអធិប្បាយណាមួយប្រតិកម្ម ប្រឆាំងនឹងអ្វីដែលលោកបានលើកឡើងនោះទេ ហើយយើងរំលឹកលោកថា លោកមិនត្រូវលើកបញ្ហាដដែលនេះទៀតទេ។

[10] ឯកសារ E1/31.1 ប្រតិចារិតនៃដំណើរការជំនុំជម្រះ ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១២ (ថ្ងៃសវនាការទី១៩) ERN 00772575–00772677, ទំព័រ 2:12–15 ។

[11] ដូចខាងលើ ទំព័រ ២:២០-២៥ (យើងសូមប្រគល់វេទិកានេះទៅអ្នកស្រីចៅក្រម Silvia Cartwright ដើម្បីឆ្លើយតបទៅនឹងការកត់សម្គាល់ដោយមេធាវីការពារ នួន ជា ទាក់ទងនឹងបញ្ហានេះ វាជាលើកទីបីហើយដែលមេធាវីការពារបានលើកបញ្ហានេះ បើទោះបីយើងបានជម្រាបមេធាវីពីថ្ងៃព្រហស្បតិ៍រួចហើយ ។ ដូច្នេះដើម្បីបំភ្លឺ អ្នកស្រីចៅក្រម Silvia Cartwright អាចបញ្ជាក់ពីបញ្ហានេះ ។

ណាឲ្យទាន់ពេលវេលានិងនៅពេលវេលាសមស្រប[12]។ បើទោះបីជាលោកស្រីចៅក្រមលើកផ្ទុយ ក៏មិនមានការចង្អុលបង្ហាញឲ្យបានច្បាស់លាស់ពីអង្គជំនុំជម្រះសាលាដំបូងដែរ ចំពោះសំណើផ្ទាល់មាត់នេះ[13]។

៦. ក្នុងការឆ្លើយតបនឹងការប៉ុនប៉ងរបស់មេធាវីការពារក្តីដែលចោទប្រកាន់លើសេចក្តីថ្លែងការ លោកនាយករដ្ឋមន្ត្រីព្យាយាមនិយាយសម្រួលដល់ផលប៉ះពាល់ដោយសេក្តីថ្លែងការរបស់លោកថា៖

> លោកបាននិយាយថា "ខ្ញុំចង់ធ្វើសេចក្តីថ្លែងការជាសាធារណៈអំពីមេធាវីការពារក្តីបងធំទី២ ដែលចង់ប្តឹងខ្ញុំ" ដែលសូមឲ្យមានការឆ្លើយតបពីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន។ "ខ្ញុំត្រូវបានគេសួរនៅប្រទេសវៀតណាមអំពីឧក្រិដ្ឋកម្មនៅក្នុងសម័យខ្មែរក្រហម ក៏ប៉ុន្តែមេធាវីការពារក្តីរបស់លោក នួន ជា ចោទខ្ញុំអំពីការជ្រៀតជ្រែកក្នុងកិច្ចការតុលាការ។ "សេចក្តីថ្លែងការរបស់ខ្ញុំអំពី ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី គឺមិនមានឥទ្ធិពលអ្វីលើតុលាការក្នុងពេលនេះទេ""[14]។

---

[12] ដូចខាងលើ ទំព័រ ៣:៣-១៤ (អរគុណលោកប្រធាន ។ ខ្ញុំមិនមានវត្តមាននៅទីនេះទេនៅពេលលោកប្រធានលើកបញ្ហានេះជាលើកទី២ ឬលើកទី ៣ កាលពីសប្តាហ៍មុន ។ សូមក្រោកឈរឡើងនៅពេលយើងនិយាយទៅកាន់អ្នក ។ អរគុណ ។ ខ្ញុំមិនមានវត្តមាននៅទីនេះទេនៅពេលបញ្ហានេះត្រូវបានលើកឡើងម្តងទៀតកាលពីសប្តាហ៍មុន។ ខ្ញុំត្រូវបានជូនដំណឹងថាលោកប្រធានបានមានប្រសាសន៍យ៉ាងច្បាស់ថាអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើបញ្ហានេះ ហើយថា លោកត្រូវបានស្នើសុំមិនឲ្យលើកបញ្ហានេះតទៅទៀតទេ ។ បញ្ហានឹងត្រូវបានពិចារណានៅពេលវេលាឆាប់ៗនេះ និងនៅពេលសមស្រប ។ វាមិនចាំបាច់ក្រើនរំលឹកបញ្ហានេះទៅមេធាវីការពារក្តីដែលបានដឹងបញ្ហានេះរួចមកហើយទេ ។

[13] ដូចខាងលើ ទំព័រ ៣:៣-១៤ (អរគុណលោកប្រធាន ។ ខ្ញុំមិនមានវត្តមាននៅទីនេះទេនៅពេលលោកប្រធានលើកបញ្ហានេះជាលើកទី២ ឬលើកទី ៣ កាលពីសប្តាហ៍មុន ។ សូមក្រោកឈរឡើងនៅពេលយើងនិយាយទៅកាន់អ្នក ។ អរគុណ ។ ខ្ញុំមិនមានវត្តមាននៅទីនេះទេនៅពេលបញ្ហានេះត្រូវបានលើកឡើងម្តងទៀតកាលពីសប្តាហ៍មុន។ ខ្ញុំត្រូវបានជូនដំណឹងថាលោកប្រធានបានមានប្រសាសន៍យ៉ាងច្បាស់ថាអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើបញ្ហានេះ ហើយថាលោកត្រូវបានស្នើសុំមិនឲ្យលើកបញ្ហានេះតទៅទៀតទេ ។ បញ្ហានឹងត្រូវបានពិចារណានៅពេលវេលាឆាប់ៗនេះ និងនៅពេលសមស្រប ។ វាមិនចាំបាច់ក្រើនរំលឹកបញ្ហានេះទៅមេធាវីការពារក្តីដែលបានដឹងបញ្ហានេះរួចមកហើយទេ ។

[14] *The Cambodia Herald*, 'Hun Sen calls for government response to accusations by Nuon Chea's lawyer', 18 February 2012 (available at www.thecambodiaherald.com).

លើសពីនេះទៀតនោះ គឺការលើកឡើងចុងក្រោយរបស់គាត់ថា "តុលាការអាចធ្វើអ្វីបានតាមខ្លួនចង់ *ក៏ប៉ុន្តែខ្ញុំមានសិទ្ធិថ្កោលទោសមេដឹកនាំខ្មែរក្រហម*"[15]។ ក៏ប៉ុន្តែគាត់មិនមែនជា Montesquieu នោះទេ។

## គ.ប្រតិកម្មផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង

៧. ដប់បួនថ្ងៃបន្ទាប់ពីសំណើផ្ទាល់មាត់នេះ និងដោយគ្មានការនិយាយយោងអ្វីទាល់តែសោះទៅលើលោក ហ៊ុន សែន អង្គជំនុំជម្រះសាលាដំបូង បានប្រកាសច្រានចោលពាក្យសុំនេះ៖

> មុនពេលផ្អាកសវនាការ អង្គជំនុំជម្រះសូមធ្វើសេចក្តីប្រកាសលើសេចក្តីសម្រេចទាក់ទងនឹងមេធាវីការពារក្តីលោក នួន ជា គឺលោក Pestman។ សូមលោកក្រោកឈរ។ នេះគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្តិកម្មដែលលើកឡើងដោយមេធាវីការពារក្តីអន្តរជាតិ ទាក់ទងនឹងការថ្លែងជាសាធារណៈអំពីអត្ថិភាព [sic] បទល្មើសនៃកូនក្តីរបស់គាត់។ អង្គជំនុំជម្រះបានកត់សម្គាល់នូវអញ្ញត្តិកម្មដែលលើកឡើងដោយមេធាវីការពារក្តីដែលថាការថ្លែងជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយដោយលើកឡើងពីកូនក្តីរបស់គាត់គឺលោក នួន ជា ថាមានពិរុទ្ធភាពនៃបទល្មើសដែលគាត់កំពុងត្រូវបានជំនុំជម្រះនៅពេលបច្ចុប្បន្ននេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថាមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា៖"ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ ដូច្នេះ ការសម្រេចថាមានទោស ឬគ្មានទោសនោះ គឺជាការទទួលខុសត្រូវតែមួយគត់របស់អង្គជំនុំជម្រះសាលាដំបូងដែលនឹងត្រូវពិចារណាគ្រប់អង្គហេតុ ភស្តុតាង សារណា និងច្បាប់អនុវត្តនៅ អវតក ដែលពាក់ព័ន្ធទាំងអស់។ ដូច្នេះតុលាការនឹងមិនពិចារណារាល់ការថ្លែងជាសាធារណៈណាមួយទាក់ទងនឹងពិរុទ្ធភាព ឬនិរទោសរបស់ជនជាប់ចោទដើម្បីឈានដល់ការចេញសាលក្រមរបស់ខ្លួននោះឡើយ[16]។

---

[15] ដូចខាងលើ។ មើលផងដែរ Vong Sokheng & David Boyle, *The Phnom Penh Post*, 'KR leadership fair game: PM' ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ (នៅក្នុងវេទិការាជរដ្ឋាភិបាលជាមួយនិងអង្គការមិនមែនរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រីបាននិយាយថាគាត់មិនទាន់ត្រូវបានដកសិទ្ធិឱ្យនិយាយអំពីបទឧក្រិដ្ឋរបស់ នួន ជា នៅក្នុងសម័យខ្មែរក្រហម។ "ការហាមឃាត់មិនឱ្យខ្ញុំនិយាយថ្កោលទោស នួន ជា ប៉ុល ពត មានតែខ្ញុំខុសក្នុងការវាយរំលំរបបប៉ុលពត"។ "មើលទាំងអស់ជួយការពារខ្ញុំមើល ហើយកុំឱ្យមេធាវីការពារក្តីឱ្យ នួន ជា ក្អេងក្អាងពេក។"

[16] ឯកសារ **E1/38.1**, ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ (ថ្ងៃជំនុំជម្រះទី២៦), ERN 00777033–00777149, ទំព័រ១១៣: ២–២២។

គួរកត់សម្គាល់ផងដែរថា ក្នុងការចេញ "សេចក្តីសម្រេចដែលមិនមែនជាសេចក្តីសម្រេច"នេះ (non-decision) ប្រធានអង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីការរំលោភសិទ្ធិមនុស្ស និងយុត្តិសាស្ត្រគាំទ្រដែលមេធាវីការពារក្តីបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងសវនាការឡើយ[17]។ ក្រៅតែពីការលើកឡើងយ៉ាងច្បាស់ថាអង្គជំនុំជម្រះសាលាដំបូងត្រូវបានចងដោយរដ្ឋធម្មនុញ្ញ ប្រធានអង្គជំនុំជម្រះសាលាដំបូង មិនបានបញ្ជាក់អ្វីទាំងអស់ដែលអាចត្រូវបានគេចាត់ទុកបានថាជាសេចក្តីសម្រេចនោះទេ ។ ខណៈពេលដែលមេធាវីការពារក្តីមានបំណងលើកឡើងពីបញ្ហានេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រាប់មេធាវីការពារក្តីដោយប្រើភាសាមិនសមរម្យ ថាអង្គជំនុំជម្រះមិនមានបំណងដោះស្រាយបញ្ហានេះបន្តទៀតនៅក្នុងសវនាការទេដោយសារតែមូលហេតុ ដែលនៅតែមិនទាន់ដឹង និងមិនទាន់យកមកបង្ហាញ[18]។

## III. អង្គច្បាប់ពាក់ព័ន្ធ

### ក.ការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ

៨. យោងតាមវិធាន៣៥(១) នៃវិធានផ្ទៃក្នុង "អង្គជំនុំជម្រះអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[19]"។ ប្រសិនបើអង្គជំនុំជម្រះ 'មានហេតុផលជឿថាបុគ្គលម្នាក់ *"អាចធ្លាប់បានប្រព្រឹត្ត* ការជ្រៀតជ្រែកបែបនេះ អង្គជំនុំជម្រះអាច (ក) ដោះស្រាយបញ្ហានេះជាបន្ទាន់ (ខ) ធ្វើការស៊ើបអង្កេតបន្ថែមទៀតដើម្បីឲ្យដឹងថាតើមានមូលហេតុគ្រប់គ្រាន់ដែរឬទេសម្រាប់ចាប់ផ្តើមនីតិវិធី ឬ (គ) យកបញ្ហានេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិដោះស្រាយ*'[20]* ។

---

[17] សូមមើល លេខជើងទំព័រ ៣ ខាងលើ។

[18] ឯកសារ **E1/40.1**, ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ថ្ងៃជំនុំជម្រះទី២៨), 00778434–00778489, ទំព័រ៩: ៩–៨ :៤។

[19] *កំណត់សម្គាល់* វិធាន៣៥(១) ចែងពីបញ្ជីទំលំទូលាយអំពីឧទាហរណ៍នៃការជ្រៀតជ្រែកបែបនេះ។

[20] វិធាន៣៥(២) (គូសបញ្ជាក់បន្ថែម)។

៩. ដោយផ្អែកលើខ្លឹមសារនៃវិធាន៣៥នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិជាធរមានស្រដៀងគ្នានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយោហ្គោស្លាវី ("ICTY") អង្គបុរេជំនុំជម្រះបានកំណត់ថា "*មានបទដ្ឋានភស្តុតាងខុសប្លែកគ្នាបី* ដែលតម្រូវឲ្យមានចំណាប់អារម្មណ៍នៅពេលពិចារណាអំពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង"[21] ។

> បទដ្ឋានទាំងនេះគឺ (i) ហេតុផលដែលអាចជឿជាក់ (ii) ហេតុផលគ្រប់គ្រាន់ (iii) ឲ្យហួសពីវិមតិ្តសង្ស័យ។ បទដ្ឋាននៃហេតុផលជឿជាក់ ត្រូវបានបញ្ជាក់ក្នុងវិធាន ៣៥(២) ដែលបានផ្តល់នូវវិធានការបីចំណុចនៅពេលអង្គជំនុំជម្រះមានហេតុផលជឿថាបុគ្គលម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយដូចចែងក្នុងវិធាន ៣៥(១)។ បទដ្ឋាននៃហេតុផលគ្រប់គ្រាន់ត្រូវតែបានបំពេញដើម្បីចាប់ផ្តើមនីតិវិធី ដើម្បីដោះស្រាយបញ្ហានេះជាបន្ទាន់ ឬប្រគល់បញ្ហានេះឲ្យអាជ្ញាធរកម្ពុជា ឬអង្គការសហប្រជាជាតិជាអ្នកដោះស្រាយ។ បទដ្ឋានហួសពីវិមតិ្តសង្ស័យនៃភស្តុតាងត្រូវបានបំពេញ នៅមុនពេលមានការដាក់ទណ្ឌកម្មណាមួយលើបុគ្គលម្នាក់ពីបទរំលោភវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង[22]។

យោងតាមអង្គបុរេជំនុំជម្រះ "បទដ្ឋាននៃហេតុផលដែលអាចជឿជាក់បាន គឺមានកម្រិតទាបបំផុត ឬគ្រាន់តែតម្រូវឲ្យមានការស៊ើបអង្កេតដោយ[...]អង្គជំនុំជម្រះតែប៉ុណ្ណោះ"[23]។

១០. បទប្បញ្ញត្តិសំខាន់មួយដើម្បីរក្សាអនាគតិ និងឯករាជ្យភាពរបស់ អវតក និងដើម្បីធានាបន្ថែមទៀត

---

[21] ឯកសារលេខ **D-314/1/12** "សេចក្តីសម្រេចទី២លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹង ដីការ កសចស" ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២, ERN 00600748–00600774 កថាខណ្ឌ៣៦ (គូសបញ្ជាក់បន្ថែម)។

[22] ដូចគ្នាជើងទំព័រខាងលើ (គូសបញ្ជាក់តាមច្បាប់ដើម)។

[23] ដូចគ្នាជើងទំព័រខាងលើ, កថាខណ្ឌទី៣៧ (គូសបញ្ជាក់បន្ថែម)។ កត់សម្គាល់ លក្ខណៈទូទៅនៃការកម្រិតនេះត្រូវបានបញ្ជាក់ដោយការ ដាក់បញ្ចូលពាក្យថា *អាច* ដូចដែលបានចែងក្នុងវិធាន៣៥ (២) នៃវិធានផ្ទៃក្នុង។ ការរកឃើញដែលថាមានមូលហេតុអាចជឿជាក់បាន គឺមិនតម្រូវ ឬ ពាក់ព័ន្ធទៅនឹងការកំណត់ទាក់ទងនឹងភាពត្រឹមត្រូវនៃការចោទប្រកាន់ ឬការសង្ស័យអំពីការ ជ្រៀតជ្រែកឡើយ។ ប៉ុន្តែការរកឃើញដែលថាបទដ្ឋាននៃមូលហេតុដែលអាចជឿជាក់ត្រូវបានបំពេញនោះ តម្រូវឲ្យ កសច ឬ អង្គជំនុំជម្រះសន្និដ្ឋានបានថាពិតជាមានការលម្អៀងដ៏សំខាន់ ឬក៏ហេតុផលដែលជាគ្រឹះនៃជំនឿរបស់ពួកគេ។ ការលម្អៀង ឬហេតុផលបែបនេះត្រូវតែបង្កើតឡើងដោយផ្អែកលើការត្រួតពិនិត្យអំពីការចោទប្រកាន់ ឬការសង្ស័យ"។ ដូចគ្នាជើងទំព័រខាងលើ, សូមមើលផងដែរជើងទំព័រខាងលើ, កថាខណ្ឌ៣៨,៣៩ (ទាក់ទងនឹងបទដ្ឋាននៃមូល ហេតុគ្រប់គ្រាន់ និងហួសពីវិមតិសង្ស័យ)។

នូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ វិធាន៣៥ គឺមានសារៈសំខាន់ខ្លាំងណាស់។

> វិធាន៣៥ ត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុងជាយន្តការណ៍មួយដើម្បីរក្សាសុចរិតភាព នៃដំណើរការតុលាការទាំងនៅក្នុងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ។ សុចរិតភាពនៃដំណើការតុលាការត្រូវបានធានាតាមរយៈការអនុវត្តប្រកបដោយសុភវិនិច្ឆ័យ នូវវិធាននេះនៅពេលដែល [...] អង្គជំនុំជម្រះពិចារណាថាទង្វើណាមួយដែលប្រព្រឹត្តដោយ បុគ្គលម្នាក់បានគំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់តុលាការ។ ការអនុវត្តបទប្បញ្ញត្តិនេះ *សូម្បីតែនៅពេលដែលគ្មានផលប៉ះពាល់ភ្លាមៗណាមួយលើ [...] សេចក្តីសម្រេចរបស់ តុលាការក៏ដោយ* គឺជាការរារាំងដល់អ្នកដែលគេគិតថាមានឥទ្ធិពលលើដំណើររបស់តុលាការវិធាននេះក៏ជម្រុញឲ្យមានទំនុកចិត្តផងដែរទាំងទៅលើបុគ្គលដែលធ្វើសេចក្តីថ្លែងការណ៍ និងបុគ្គលដែលអាចពិចារណាពីការផ្តល់ភស្តុតាងដែល*[...]*អង្គជំនុំជម្រះនឹង*ចាត់វិធានការណ៍ដោយគ្មានការស្ទាក់ស្ទើរ* ចំពោះបុគ្គលដែលមានបំណងរារាំង ឬធ្វើឲ្យការពាក់ព័ន្ធរបស់ពួកគេ មានឥទ្ធិពលទៅលើ អវតក។ ធ្វើដូច្នេះ ភាពអាចជឿជាក់បាននៃនីតិវិធីនៅចំពោះមុខ អវតក ទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ នឹងត្រូវបានរក្សា[24]។

ដោយសារតែមុខងារខាងការពារ និងការអនុវត្តជាទូទៅរបស់វា[25] អង្គបុរេជំនុំជម្រះបានផ្តល់យ៉ាងត្រឹមត្រូវនូវការបកស្រាយយ៉ាងទូលំទូលាយដល់វិធាន៣៥។

## ខ.ការសន្មតទុកជាមុនថាគ្មានទោស

១១. មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់ពីការសន្មតទុកជាមុនថាគ្មានទោសដែលផ្តល់ឲ្យបុគ្គលគ្រប់រូបដែលប្រឈមនឹងការចោទប្រកាន់ព្រហ្មទណ្ឌ៖“ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកឥតទោស

---

[24] ឯកសារ **D-314/2/7**, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកា សម្រេចរបស់ កសចស លើសំណើសុំកោះហៅសាក្សី, ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១០, ERN 00527392–00527420 (“ដីកាសម្រេចលើសំណើសុំកោះហៅសាក្សី”) កថាខណ្ឌ៣៨ (គូសបញ្ជាក់បន្ថែម)។

[25] *កំណត់សម្គាល់* វិធាន៣៥ ស្ថិតនៅក្រោមនិទ្ទេសបទនៃវិធានទាំងនេះ៖ “III. និតិវិធី, ក.បទប្បញ្ញត្តិទូទៅ”។

ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"[26]។ ការធានានេះគឺដូចគ្នានឹងការធានាដែលបានផ្តល់ឲ្យនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្សដទៃទៀតនៅលើពិភពលោក។ ជាពិសេស មាត្រា៦(២) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(ECHR)ចែងថា៖ "បុគ្គលគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតទល់តែពិរុទ្ធភាពត្រូវបានរកឃើញស្របតាមច្បាប់" ។

១២. តុលាការអឺរ៉ុបសិទ្ធិមនុស្ស (ECtHR) បានអះអាងជាយូរយារណាស់មកហើយថាការសន្មតទុកជាមុនថាគ្មានទោសត្រូវយកមកអនុវត្តចំពោះតួអង្គដែលមិនមែនជាមន្ត្រីតុលាការ និងអាចត្រូវបានរំលោភដោយបុគ្គលដែលមានមុខងារសាធារណៈខ្ពស់។ ក្នុងរឿងក្តីដ៏សំខាន់របស់ខ្លួនដែលទាក់ទងនឹងបញ្ហានេះ (រឿងក្តី Ribemont តទល់នឹងប្រទេសបារាំង)[27] រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបារាំង (ជាមួយនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួនទៀត) បានធ្វើការថ្លែងជាសាធារណៈ(នៅក្នុងសន្និសីទសារព័ត៌មាន) ដោយលើកឡើងថា ម្ចាស់បណ្តឹងបានពាក់ព័ន្ធដោយគ្មានមន្ទិលសង្ស័យជាមួយនឹងឧក្រិដ្ឋកម្មដែលគាត់មិនទាន់ត្រូវបានគេចោទប្រកាន់និងយកទៅជំនុំជម្រះនៅឡើយ[28]។

១៣. តុលាការពិចារណាឃើញថា "ការលើកឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺផ្ទុយពីគោលការដែលសន្មតទុកជាមុនថា គ្មានទោស"[29]។ ជាពិសេស៖

> តុលាការកត់សម្គាល់ឃើញថា នៅក្នុងរឿងក្តីនេះ មន្ត្រីជាន់ខ្ពស់មួយចំនួននៅក្នុងនគរបាលបារាំងបានចាត់ទុកលោក Allenet de Ribemont ដោយគ្មានការកំណត់ព្រំដែន ឬការសង្ស័យណាមួយថាជាអ្នកផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមដទៃទៀតនៃរឿងឃាតកម្ម និងជាអ្នកផ្សំគំនិតក្នុងរឿងឃាតកម្មនោះ។ នេះគឺជាការប្រកាសយ៉ាងច្បាស់អំពីពិរុទ្ធភាពរបស់អ្នកប្តឹងដែលការប្រកាសបែបនេះទី១គឺជម្រុញឲ្យសាធារណៈជនជឿជាក់ថា គាត់ពិតជាមានពិរុទ្ធភាព និងទី២វិនិច្ឆ័យទុកជាមុនលើការវាយតម្លៃអំពីអង្គហេតុដោយអាជ្ញាធរតុលាការមានសមត្ថ

[26] កំរងច្បាប់របស់ អវតក, ឯកសារ (អនុម័តកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ក្នុងទីក្រុងភ្នំពេញដោយរដ្ឋសភាជាតិ នីតិការទីពីររបស់ខ្លួន)។

[27] រឿងក្តី Ribemont តទល់នឹងប្រទេសបារាំង, សំណើរបស់អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, លេខ 1517589, "សេចក្តីសម្រេច", ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៥។ កថាខណ្ឌ36។ ("តុលាការចាត់ទុកថា ការសន្មត់ទុកជាមុនថាគ្មានទោសអាចត្រូវបានរំលោភ មិនត្រឹមតែចៅក្រម ឬតុលាការទេ តែដោយមន្ត្រីសាធារណៈផងដែរ") (បញ្ជាក់បន្ថែម)។

[28] រឿងក្តី Ribemont, កថាខណ្ឌ១០ ដល់ ១២។

[29] រឿងក្តី Ribemont, កថាខណ្ឌ៣៩។

កិច្ច[30]។

ការលើកឡើងដោយរដ្ឋមន្ត្រីគឺជាការរំលោភមាត្រា៦(២) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស][31]។ តុលាការក៏បានពន្យល់ផងដែរថា បើទោះជាអជ្ញាធរមានសិទ្ធិក្នុងការ "ជូនដំណឹង [...] ដល់សាធារណៈជនអំពីការស៊ើបអង្កេតព្រហ្មទណ្ឌដែលកំពុងធ្វើឡើងក៏ដោយ" តែច្បាប់"តម្រូវឱ្យធ្វើដូច្នេះដោយមិនប៉ះពាល់ដល់ភាគីណាមួយ និងដោយប្រុងប្រយ័ត្នដើម្បីគោរពដល់គោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោស"[32]។ សេចក្តីសម្រេច Ribemont បន្ទាប់មក និងបន្តមកទៀតត្រូវបានទទួលយកដោយតុលាការអឺរ៉ុបសិទ្ធិមនុស្ស[33] ។

១៤. ពាក់ព័ន្ធនឹងបញ្ហានេះ វាជាការចាំបាច់ក្នុងការគិតទៅដល់សេចក្តីថ្លែងការជាសាធារណៈរបស់ចៅក្រម Cartwright ក្នុងការឆ្លើយតបទៅនឹងការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងឆ្នាំ ២00៩៖

> ឋានៈជានាយករដ្ឋមន្ត្រីលោក ហ៊ុន សែន និយាយថា គាត់ទន្ទឹងរង់ចាំតុលាការកាត់ក្តីប្រឆាំងនឹងពួកបនប៉ុលពត។ ចៅក្រម Cartwright និយាយថា ការជ្រៀតជ្រែកខាងនយោបាយក្នុងដំណើការតុលាការគឺជារឿងអាក្រក់។ [...]
>
> លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន [...] បានបញ្ជាក់ពីការមើលងាយដល់តុលាការ និងបានបញ្ជាក់យ៉ាងច្បាស់ថាគាត់ចង់ឱ្យតុលាការនេះចប់ឆាប់ៗ។ [...]
>
> លោក ហ៊ុន សែន បាននិយាយថា "ខ្ញុំបន់ឱ្យតុលាការនេះអស់លុយឱ្យឆាប់ទៅ ដូចនេះចៅក្រមបរទេស និង

---

[30] រឿងក្តី Ribemont, កថាខណ្ឌ៤១។

[31] រឿងក្តី Ribemont, កថាខណ្ឌ៤១។

[32] រឿងក្តី Ribemont, កថាខណ្ឌ៣៨។

[33] សូមមើលឧទាហរណ៍, រឿងក្តី *Fatuallayev តទល់នឹងប្រទេស Azerbaijan* , ពាក្យសុំរបស់ ECtHR, លេខ40984/07, "សេចក្តីសម្រេច", ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២0១0, កថាខណ្ឌ១៥៧ ដល់១៦៣។ រឿងក្តី *ButkeviČius តទល់នឹងប្រទេស Lithuania*, ពាក្យសុំរបស់ ECtHR, លេខ 48297/99, "សេចក្តីសម្រេច", ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២00២, កថាខណ្ឌ៤៦ ដល់៥៤។ រឿងក្តី *Khuzhin និងអ្នកដទៃទៀត តទល់នឹងប្រទេស រុស្ស៊ី*, ពាក្យសុំរបស់ ECtHR, លេខ13470/02, "សេចក្តីសម្រេច", ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២00៨, កថាខណ្ឌ៩៣ដល់៩៧។

ព្រះរាជអាជ្ញាដើរចេញ”។

“ដូចនេះអាចឲ្យកម្ពុជា បញ្ចប់តុលាការដោយខ្លួនឯង”។

សន្ទរកថាលោកនាយករដ្ឋមន្ត្រី ក៏បញ្ជាក់ផងដែរថាមន្ត្រីដែលតំណាងរដ្ឋាភិបាលគឺថិតនៅក្រោមឥទ្ធិពលរបស់គាត់។

ចៅក្រម Cartwright មិនលើកឡើងដោយផ្ទាល់ថា វាជារឿងនយោបាយ ប៉ុន្តែគាត់ច្បាស់ជាមិនចាប់អារម្មណ៍នឹងការវាយប្រហារដោយពាក្យសំដីនេះ។

លោកស្រីចៅក្រមបាននិយាយថា “នៅប្រទេសដែលនីតិរដ្ឋត្រូវបានគោរព និងប្រជាពលរដ្ឋអាចទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌ ភាពឯករាជ្យនៃតុលាការ និងចៅក្រមត្រូវបានធានា”។

“សេចក្តីថ្លែងការ ដែលមានចេតនា នយោបាយ ដែលជាការប៉ុនប៉ងជ្រៀតជ្រែកលើឯករាជ្យភាព គឺត្រូវតែជំទាស់”[34]។

ដូចដែលមេធាវីអន្តរជាតិបានលើកឡើងក្នុងពេលថ្មីៗនេះក្នុងសវនាការទាក់ទងនឹងការលើកឡើងរបស់ចៅក្រម Cartwright មេធាវីការពារក្តីមិនអាចពន្យល់ឲ្យបានល្អជាងនេះទៀតទេ[35]។

## គ.សំណងដោយសមធម៌ចំពោះការខូចខាតដែលមិនទាក់ទងនឹងប្រាក់កាស

១៥. តុលាការយល់ឃើញ*ក្នុងចំណោមបញ្ហាដទៃទៀត*ថាអ្នកប្តឹងពិតជាបានទទួលរងនូវការខូចខាតដែលមិន

---

[34] Maggie Tait, ‘Interference “deplored” by judge’, Stuff New Zealand (NZPA), 5 April 2009 (available at http://www.stuff.co.nz/world/asia/2315921/Interference-deplored-by-judge) (emphasis added).

[35] ឯកសារ **E1/38.1,** ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ (ថ្ងៃជំនុំជម្រះទី២៦), ERN 00777033–00777149, ទំព័រ៧៧: ១៤–១៦។

ទាក់ទងនឹងប្រាក់កាសដោយសារតែការរំលោភលើសិទ្ធិរបស់ខ្លួន[36]។ ដោយពិនិត្យឃើញថាគេអាចសន្មតទុកមុនថាប្រព័ន្ធផ្សព្វផ្សាយនឹងចុះផ្សាយពីការថ្លែង [ដែលកំពុងយកមកពិភាក្សា] នេះយ៉ាងទូលំទូលាយនោះ "ភាពខ្វះដែនកំណត់និងការប្រុងប្រយ័ត្ន"នៅពេលធ្វើការថ្លែងអំពីអ្នកប្តឹងគឺរិតតែជារឿងមួយដែលអាក្រក់ជាងនេះទៀត។ ជាងនេះទៅទៀត ការថ្លែងនេះគឺត្រូវបានរាយការណ៍យ៉ាងទូលំទូលាយទាំងនៅក្នុងប្រទេសបារាំង និងនៅបរទេស"[37]។ "ដោយធ្វើការពិចារណាទៅលើកត្តាពាក់ព័ន្ធផ្សេងៗ និងដោយធ្វើការវាយ តម្លៃរបស់ខ្លួនដោយឈរលើមូលដ្ឋានសមធម៌" តុលាការបានផ្តល់ឲ្យអ្នកប្តឹងនូវ "ទឹកប្រាក់សរុបចំនួន ២,០០០,០០០ ហ្វ្រង់" សម្រាប់សំណងដែលប៉ះពាល់ដោយសេចក្តីថ្លែងការជាសាធារណៈរបស់លោករដ្ឋមន្ត្រី[38]។ តាមរយៈការវាយតម្លៃទាំងនេះ "អនុសញ្ញាត្រូវតែបកស្រាយក្នុងន័យធានានូវសិទ្ធិ *ដែលប្រកបដោយប្រសិទ្ធិភាព និងផលប្រយោជន៍ដោយផ្ទុយទៅនឹងតាមទ្រឹស្តីនិងដែលបំភាន់*"[39]។

## IV.ឧទ្ទិករណ៍

### ក.សំណើនេះអាចទទួលយកបាន

១៦. អង្គជំនុំជម្រះមានអំណាចក្នុងការដាក់ទណ្ឌកម្ម "បុគ្គលដែលមានបំណង និងចេតនាជ្រៀតជ្រែកមកក្នុងកិច្ចការតុលាការ"[40]។ ការជ្រៀតជ្រែកកំណត់យ៉ាងទូលំទូលាយដោយវិធាន និងបកស្រាយយ៉ាងទូលាយដោយយុត្តិសាស្ត្រដែលពាក់ព័ន្ធ[41]។ វិធាន ៣៥ រាប់បញ្ចូលយ៉ាងច្បាស់ក្នុងការយល់របស់ខ្លួនអំពីការប្រព្រឹត្តដោយលោកនាយករដ្ឋមន្ត្រី។ អង្គជំនុំជម្រះនេះ ក៏ដូចជា អបជ និង អង្គជំនុំជម្រះតុលា

[36] រឿងក្តី Ribemont, កថាខណ្ឌ៦២។ តុលាការក៏បានគាំទ្រផងដែរនូវការខូចខាតជាថវិការដោយផ្អែកទៅលើការលំបាក របស់អ្នកប្តឹងក្នុងការបន្តមុខងាររបស់គាត់ដោយសារតែការបាត់ទំនុកចិត្តពីអ្នកដែលធ្វើជំនួញជាមួយគាត់។ ដូចគ្នា។

[37] រឿងក្តី Ribemont, កថាខណ្ឌ៦២។

[38] រឿងក្តី Ribemont, កថាខណ្ឌ៦២។

[39] រឿងក្តី Ribemont, កថាខណ្ឌ ៣៥។ (ដកស្រង់ក្នុងg *Artico v Italy*, ECtHR App No 6694/74, 'សាលក្រម', ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ១៩៨០) កថាខណ្ឌ ៣៣។

[40] វិធាន ៣៥(១)។

[41] សូមមើលកថាខណ្ឌទី ៩ ដល់ ១០ ខាងលើ។

ការកំពូលដែរ ទទួលស្គាល់ថា ភាគីអាចស្នើសុំដំណោះស្រាយជាវិជ្ជមានតាមរយៈការស្នើសុំរបស់ខ្លួនដោយអនុលោមតាមវិធាន ៣៥[42]។ បើទោះជាមានការកត់សម្គាល់ដោយលោកប្រធានចៅក្រមនៅក្នុងសវនាការកាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២[43] ក៏ដោយ ក៏អង្គជំនុំជម្រះមិនចាត់ចែងឲ្យមានសំណើដោយផ្ទាល់មាត់ឡើយ ហើយតម្រូវឲ្យធ្វើសំណើជាលាយលក្ខណ៍អក្សរដូចនេះវិញ ដូចដែលបានស្នើឡើងដោយលោកប្រធាន និងដែលបានបញ្ជាក់ដោយមេធាវីការពារក្តី[44] រួមជាមួយការយោងលម្អិតទៅនឹងយុត្តិសាស្ត្រដែលពាក់ព័ន្ធ និងសំណើបន្ថែមសុំដំណោះស្រាយ។ អាស្រ័យហេតុនេះហើយសំណើនេះអាចទទួលយកបាន ហើយអង្គជំនុំជម្រះត្រូវតែដោះស្រាយដោយហ្មត់ចត់ និងចេញសេចក្តីសម្រេចដែលមានសម្អាងហេតុពេញលេញ។

## ខ. សេចក្តីថ្លែងការជាសាធារណៈរបស់លោក ហ៊ុន សែន ជាការរំលោភយ៉ាងច្បាស់លើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងចាត់ទុកថា ជាការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ

១៧. បញ្ហាចម្បងក្នុងសំណើនេះ អំពីថាតើសេចក្តីថ្លែងការជាសាធារណៈរបស់លោក ហ៊ុន សែន រំលោភលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ ឬក៏អត់នោះ គឺត្រូវតែឆ្លើយតបដោយវិជ្ជមាន។ ដូចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរឿងក្តី *Ribemont* ដែរ សេចក្តីថ្លែងការជាសាធារណៈរបស់លោក ហ៊ុន សែន គឺ "ផ្ទុយនឹងការសន្មតទុកជាមុនថាគ្មានទោស"[45]។ ជាការច្បាស់ណាស់ថា

[42] សូមមើលសេចក្តីសម្រេចលើសាក្សី កថាខណ្ឌទី ៤៣ (សម្រេចថា កសចស ដោយពន្លាតដល់អជសជ "ថា មានអំណាចតាមផ្លូវច្បាប់ក្នុងការចាត់ការស្របតាមវិធាន ៣៥ ដោយមិនគិតដល់ចរិតលក្ខណៈរបស់ព័ត៌មានពាក់ព័ន្ធនៅចំពោះមុខខ្លួន"។ ឯកសារលេខ **E-116/1/6** "សេចក្តីសង្ខេបហេតុផលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការស៊ើបអង្កេតដោយយុត្តិធម៌" ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២, ERN 00772881–00772887, កថាខណ្ឌទី ១៧ (រកឃើញថា អជសជ មិនបានរារាំងមេធាវីការពារក្តីដោយមិនត្រឹមត្រូវពីការស្នើសុំឆន្ទានុសិទ្ធិដោយអនុលោមតាមវិធាន ៣៥(២))

[43] សូមមើលកថាខណ្ឌទី ៧ ខាងលើ។

[44] សូមមើលពង្រាង "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ (សវនាការថ្ងៃទី៣៣) ទំព័រ ២៧:១០-២៨ :៦។ រឿងក្តី Ribemont, កថាខណ្ឌ៤១។

[45] រឿងក្តី Ribemont, កថាខណ្ឌ៣៩។

ការប្រកាសអំពីទោសរបស់លោក នួន ជា ដោយលោកនាយករដ្ឋមន្ត្រីបាន "ជម្រុញឲ្យសាធារណៈជនជឿជាក់ថា គាត់មានទោស" និង "ធ្វើសេចក្តីវិនិច្ឆ័យទោស មុន [អង្គជំនុំជម្រះ] ទៅទៀត[46]។

១៨. ដោយពិចារណាពីភាពសមហេតុផលនៅក្នុងរឿងក្តី *Ribemont* វាត្រូវតែសន្មតថា ផ្នែកជាច្រើនក្នុងសង្គមកម្ពុជាបានចាត់ទុក លោក នួន ជា ថា ជាឃាតករ និង ជនដែលដល់នៃអំពីប្រល័យពូជសាសន៍ដោយសារតែលោកនាយករដ្ឋមន្ត្រីបាននិយាយដូចនេះជាសាធារណៈ[47]។ ការពិតជាអកុសលនេះដោយសារតែធាតុពិតដែលឥទ្ធិពលរបស់លោក ហ៊ុន សែន នៅក្នុងប្រទេសនេះកាន់តែខ្លាំងដូចទៅនឹង "ប្រជាប្រិយភាព" របស់គាត់កំពង់តែរីករាលដាល។ វាសាមញ្ញទេ គាត់ពិតជាដូច្នេះមែន ដោយមិនចាំបាច់ស្វែងរកការធ្វើឲ្យលេចចេញជារូបរាងនៃទិដ្ឋភាពនយោបាយ និងសង្គមនៅកម្ពុជា។ រូបថតរបស់គាត់ត្រូវបានដាក់បង្ហាញនៅទីសាធារណៈ និងឯកជន ហើយរូបភាពរបស់គាត់ (អមជាមួយរូបភាព ជា ស៊ីម និង ហេង សំរិន) អាចមើលឃើញនៅគ្រប់ទីកន្លែង បើទោះបីវាមិនច្រើន ដូចរូបភាពរបស់ព្រះមហាក្សត្រផងដែរ។ ជាមេដឹកនាំផ្តាច់ការលោក ហ៊ុន សែន ថ្លែងទៅកាន់ប្រជាជាតិយ៉ាងទៀងទាត់គ្របដណ្តប់លើបញ្ហាទាំងអស់ រួមទាំងរឿងក្តីនៅតុលាការដែលមានលក្ខណៈនយោបាយបំផុតនាសព្វថ្ងៃនេះ ។ ដោយសារតែមនុស្សជាច្រើនគោរព និងមានច្រើនជាងនេះភ័យខ្លបខ្លាចរូបគាត់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងតែបង្ហាញទស្សនៈតុលាការចំពោះអ្នកទោសរបស់គាត់។ ហើយសាធារណៈជន ក៏ធ្លាប់ទទួលយក"ការពិត"ជាមូលដ្ឋាននៃសន្មតថាជាទម្លាប់នេះដែរ។ និយាយឲ្យខ្លីទៅគឺថា នៅពេល ហ៊ុន សែន និយាយ ប្រជាជនកម្ពុជាស្តាប់។ ហើយជាអកុសល ជាញឹកញាប់ប្រជាជនជឿអ្វីដែលគាត់ត្រូវតែនិយាយ។

១៩. ដូចគ្នានេះដែរអ្នកសង្កេតឯករាជ្យនៅក្នុងប្រទេសនេះនឹងយល់ថា សេចក្តីថ្លែងការរបស់លោកនាយករដ្ឋមន្ត្រីថា ជាការប៉ុនប៉ងគ្រប់គ្រងអង្គជំនុំជម្រះសាលាដំបូង ជាពិសេសគឺសមាជិកដែលជាជាតិកម្ពុជាដើម្បីឲ្យប៉ះពាល់ដល់លទ្ធផលក្នុងសំណុំរឿងប្រឆាំងនឹងលោក នួន ជា គឺការផ្តន្ទាទោស។ នៅគ្រាមួយនោះ ហ៊ុន សែន បានប្រើពាក្យសំដីខ្លួនឯងថា *ថ្កោលទោស* នួន ជា[48] សំដីចុងក្រោយនេះហាក់ដូចជាធ្វើឲ្យលោក នួន ជា គ្មានឱកាសក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌នោះទេ។ អ្នកសង្កេតការ

[46] រឿងក្តី Ribemont, កថាខណ្ឌ៤១។

[47] សូមមើលកថាខណ្ឌទី១២ ដល់ ១៣ ខាងលើ។

[48] សូមមើលកថាខណ្ឌទី៦ ខាងលើ។

ឯករាជ្យយល់ច្បាស់ថា អ្នកច្បាប់កម្ពុជាត្រូវបានបង្វឹកយ៉ាងល្អ (មិនប្រសប់ពេក) ក្នុងសិល្បក្នុងការទទួលយកពាក្យប្រលយពីលោកនាយករដ្ឋមន្ត្រីនោះទេ។

២០. ដូចដែលមេធាវីការពារក្តីបានប្តឹងទៅតុលាការក្រុងអំពីការប្រព្រឹត្តរបស់លោក ហ៊ុន សែន រួមទាំងសេចក្តីថ្លែងការរបស់គាត់ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ ដែលបង្កើតបានជាបទឧក្រិដ្ឋនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា។ ប៉ុន្តែនេះជាបញ្ហាមួយផ្សេងទៀត។ អ្វីដែលត្រូវបានចោទប្រកាន់នៅទីនេះគឺជាការរំលោភមួយយ៉ាងច្បាស់លើសិទ្ធិជាមូលដ្ឋានរបស់លោក នួន ជា គឺការសន្មតទុកជាមុនថាគ្មានទោស។ ខណៈ "ដែលច្បាប់តម្រូវ [មន្ត្រីនិយាយជាសាធារណៈអំពីសំណុំរឿងព្រហ្មទណ្ឌដែលកំពង់រង់ចាំ] ឲ្យមានការប្រយ័ត្នប្រយែង" ដើម្បីគោរពឲ្យបានអំពីគោលការសន្មតទុកជាមុនថាគ្មានទោស[49] តែសំដីរបស់លោក ហ៊ុន សែន ធ្វើឡើងដោយមិនប្រយ័ត្នប្រយែង និងមិនកោតក្រែង។ ហើយក្នុងករណីនេះ គាត់ពិតជាបង្កើតរហូតមកដល់ពេលនេះក្នុងការគម្រាមកំហែងដល់មេធាវីការពារក្តី ដោយចាត់វិធានការតាមផ្លូវច្បាប់ ដោយគ្រាន់តែមេធាវីការពារក្តីបានលើបញ្ហាដូចមានក្នុងសំណើនេះតែប៉ុណ្ណោះ[50]។ ដូចនៅក្នុងករណី *Ribemont* គ្រាន់តែសេក្តីថ្លែងការរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (នៅខ្សោយណាស់បើប្រៀបធៀបនឹងការលើកឡើងរបស់លោក ហ៊ុន សែន) គឺវាគ្រប់គ្រាន់ណាស់ក្នុងការរំលោភលើមាត្រាទី៦(២) ដូចនេះ *a fortiori* ការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រីក្នុងបណ្តឹងនេះត្រូវតែចាត់ទុកថា ជាការរំលោភលើសិទ្ធិស្របច្បាប់របស់ នួន ជា ក្នុងការទទួលបានការសន្មតទុកជាមុនថា គ្មានទោសរហូតទាល់តែទោសទណ្ឌត្រូវបានរកឃើញ។ តាមរយៈការរំលោភនេះលោក ហ៊ុន សែន បានជ្រៀតជ្រែកក្នុងកិច្ចការរបស់តុលាការនៅ អវតក។

### គ. អង្គជំនុំជម្រះសាលាដំបូងត្រូវតែផ្តល់សំណងដោយមានប្រសិទ្ធភាព និងមានប្រយោជន៍

២១. ដូចដែលបានរៀបរាប់ពីខាងលើ ហើយដូចដែលអ្នកអង្កេតការដោយឯករាជ្យនឹងយល់ស្របថា អង្គជំនុំជម្រះមិនទាន់បានសម្រេចលើបណ្តឹងជាក់លាក់របស់មេធាវីការពារក្តី សុំឲ្យថ្កោលទោសនិងដាក់ទណ្ឌកម្ម។ ដោយអះអាងក្នុងការដោះស្រាយសំណើដោយផ្ទាល់មាត់ ក៏ប៉ុន្តែដោយពុំបានដោះស្រាយបញ្ហាជាដុំកំភួន លោកប្រធានចៅក្រមខកខាន ក្នុងការលើកឡើងសូម្បីតែឈ្មោះនាយករដ្ឋមន្ត្រី ឬក៏តួនាទីរបស់

---

[49] សូមមើលជើងទំព័រទី ១៣ ខាងលើ។

[50] សូមមើលជើងទំព័រទី ១៥ ខាងលើ។

គាត់ផង[51]។ ការខកខាននេះប្រាប់យើងដោយខ្លួនឯង។ តាមរយៈការព្យាយាមងាកចេញពីការរំលោភរបស់លោក ហ៊ុន សែន និងចូលមកពិភាក្សាអំពីសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទប់ទល់ពីការជ្រៀតជ្រែកសំណាក់ស្ថាប័ននីតិប្រតិបត្តិ[52] អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាចង់សម្រាលអង្គហេតុនៃការរំលោភយ៉ាងធ្ងន់ធ្ងរនេះទៅវិញ។ ក៏ប៉ុន្តែការប្រងើយកន្តើយ ក្រៅតែពីភាពមិនសមរម្យរបស់ខ្លួន វានឹងនាំឲ្យកាន់តែមានការខូចខាតបន្ថែមទៀតដោយសារសេចក្តីថ្លែងការរបស់លោកនាយករដ្ឋមន្ត្រី។

២២. ជាងនេះទៅទៀត ដោយគ្រាន់តែការយោងតែលើកាតព្វរបស់អង្គជំនុំជម្រះឲ្យគោរពដល់មាត្រាទី ៣៨ នៃរដ្ឋធម្មនុញ្ញ[53] ដែលជាលក្ខខណ្ឌតម្រូវយ៉ាងពិតប្រាកដសម្រាប់ចៅក្រមនៃអង្គជំនុំជម្រះនេះ បើទោះជាចំនុចចាប់ផ្តើមល្អមួយក៏ដោយ ក៏មិនគ្រប់គ្រាន់ទេក្នុងការទាត់ចោលបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី។ ការនិយាយជាសាមញ្ញអំពីការការពារដោយច្បាប់ជាធរមានគឺមិនមែនជាការការពារនោះទេ។ បើពិចារណាអំពីការរំលោភយ៉ាងច្បាស់ (ដូចដែលបានពិភាក្សានៅផ្នែកមុន) អ្វីដែលត្រូវការនោះគឺសំណងដែលមានប្រសិទ្ធិភាព និងមានប្រយោជន៍ដែលផ្តយទៅនឹងទ្រឹស្តី និងដែលបំភាន់នោះ[54] ដូចដែលបានផ្តល់ដោយអង្គជំនុំជម្រះរហូតមកដល់ថ្ងៃនេះ។ រំលឹកពីពាក្យសំដីរបស់ចៅក្រម Cartwright សេចក្តីថ្លែងការជាសាធារណៈ "ដែលជាការប៉ុនប៉ងជ្រៀតជ្រែកលើឯករាជ្យភាព[របស់តុលាការ] គឺត្រូវតែជំទាស់"[55]។ តាមពិតទៅ ដោយអនុលោមតាមយុត្តិសាស្ត្រពាក់ព័ន្ធ សេចក្តីថ្លែងការបែបនេះត្រូវតែថ្កោលទោស អ្នកបង្កើតត្រូវតែដាក់ទណ្ឌកម្ម ហើយជនរងគ្រោះត្រូវតែទទួលសំណង។ អាស្រ័យហេតុនេះហើយ អង្គជំនុំជម្រះត្រូវតែអនុវត្តដោយរឹងប៉ឹងដោយអនុលោមតាមវិធាន៣៥។

២៣. ដើម្បីការពារកុំឲ្យមានការខូចខាតបន្តទៅទៀត មេធាវីការពារក្តីបានស្នើឡើងនូវសំណងសមស្របគឺការថ្កោលទោសជាសាធារណៈលើសេចក្តីថ្លែងការរបស់លោក ហ៊ុន សែន និងការព្រមានជាសាធារណៈមួយថា សេចក្តីថ្លែងការខាងមុខនឹងត្រូវចាត់វិធានការកាន់តែតឹងរឹងថែមទៀត។ អង្គជំនុំជម្រះ

---

[51] សូមមើលកថាខណ្ឌទី ៧ ខាងលើ។

[52] ដូចខាងលើ។

[53] ដូចខាងលើ។

[54] សូមមើលកថាខណ្ឌទី ១៥ ខាងលើ។

[55] សូមមើលកថាខណ្ឌទី ១៤ ខាងលើ។

នេះមិនគ្រាន់តែមានករណីកិច្ចជាវិជ្ជមានក្នុងការប្រកាសជំទាស់នឹងសកម្មភាពដែលជ្រៀតជ្រែកក្នុងកិច្ចការតុលាការប៉ុណ្ណោះទេ តែខ្លួនក៏មិនគួរស្ទាក់ស្ទើរក្នុងការពន្យល់ទៅកាន់លោកនាយករដ្ឋមន្ត្រីនិងទៅសាធារណៈជនថា នៅក្នុងដំណើរការប្រជាធិបតេយ្យវិស័យតុលាការមិនទទួលបញ្ជាពីអង្គការនីតិប្រតិបត្តិនោះទេ។ អង្គជំនុំជម្រះត្រូវតែបង្ហាញពីឯករាជ្យភាព សមត្ថភាព និងការប្តេជ្ញារបស់ខ្លួនក្នុងការកាត់ក្តីលើរូបលោក នួន ជា ដោយយុត្តិធម៌។ ប្រសិនបើប្រទេសកម្ពុជា ជាសង្គមបើកចំហដូចដែលមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានអះអាងមែន នោះលោកប្រធានចៅក្រមនិងសហសេវិនរបស់គាត់មិនត្រូវមានការលើកលែងទៅលើសកម្មភាពរិះគន់ជាសាធារណៈរបស់លោក ហ៊ុន សែន និង សេចក្តីថ្លែងការរបស់គាត់ដែលធ្វើឲ្យខូចខាតនោះទេ។ ដូចនៅក្នុងរឿងក្តី *Ribemont* យុត្តិធម៌តម្រូវឲ្យមានសំណាង[56]។ លុះត្រាតែ និងរហូតដល់សកម្មភាពបែបនេះត្រូវបានអនុវត្តដោយអង្គជំនុំជម្រះ បើមិនដូច្នោះទេ លោកនាយករដ្ឋមន្ត្រីនឹងលើកឡើងជាថ្មីម្តងទៀតអំពី អវតក ដែលជាស្ថាប័នមួយត្រូវបានបំភិតបំភ័យនោះ។

## V. សេចក្តីសន្និដ្ឋាន

២៤. អាស្រ័យហេតុនេះសម្រាប់ហេតុផលដែលបានរៀបរាប់ក្នុងសំណើនេះ អង្គជំនុំជម្រះត្រូវតែៈ

ក. ទទួលយកសំណើនេះ

ខ. ទទួលស្គាល់ថា សេចក្តីថ្លែងការរបស់លោក ហ៊ុន សែន គឺជាការរំលោភសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការសន្មតទុកជាមុនថា គ្មានទោស និងទង្វើបែបនេះគឺជាការជ្រៀតជ្រែកមកលើកិច្ចការតុលាការនៅ អវតក

គ. ថ្កោលទោសជាសាធារណៈដល់លោកនាយករដ្ឋមន្ត្រី និងប្រមានជាផ្លូវការមួយកុំឲ្យគាត់ធ្វើសេចក្តីថ្លែងការដូចគ្នាក្នុងពេលខាងមុខទៀត។

អំណះអំណាងផ្ទាល់មាត់នៅចំពោះមុខសវនាការសាធារណៈ នៅមុនការកំណត់សេចក្តីសម្រេច គឺជាជម្រើសសមរម្យ ត្រូវបានស្នើសុំក្នុងសំណើនេះ ដោយសារពិចារណាដល់បញ្ហារបស់សំណើ និងសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។

---

[56] សូមមើលកថាខណ្ឌទី ១៥ ខាងលើ។

**សហមេធាវីការពារក្តីអន្តរជាតិលោក នួន ជា**

Michiel PESTMAN & Victor KOPPE

Andrew IANUZZI & Jasper PAUW